**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**
សំណុំរឿងរដ្ឋប្បវេណីលេខ: ៤៨៣
ចុះថ្ងៃទី២៣-ឧសភា-២០២៣
សាលក្រមលេខ: ៥១ (ន)
ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣

**តាមនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្តាល**

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង១០ និង៣០នាទីព្រឹក លើសំណុំរឿងរដ្ឋប្បវេណីលេខ: ៤៨៣ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ ដែលមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជី**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

**គូភាគីជាអាទិ៍៖**

-**<u>រវាងដើមចោទ</u>**: ឈ្មោះ [redacted] ស្រីពៅ ភេទស្រី កើតឆ្នាំ១៩៩៣ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted]

-**អ្នកតំណាងដោយអាណត្តិ**: លោកមេធាវី [redacted]ត្តលេខ២៧០២ T ក្រុមមេធាវី [redacted] អាសយដ្ឋានផ្ទះលេខ [redacted] និងលោកមេធាវី [redacted] អាសយដ្ឋាន [redacted]

-**<u>និងចុងចម្លើយ</u>**: ឈ្មោះ [redacted] រ៉ានី ភេទប្រុស កើតឆ្នាំ១៩៨៧ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted]។

**<u>អង្គហេតុ និងចំណុចវិវាទ</u>**

**១- ខ្លឹមសារនៃសាលក្រមដែលដើមចោទប្តឹងសុំឲ្យតុលាការចេញ៖**

១- ស្នើសុំលែងលះរវាងដើមចោទ និងចុងចម្លើយ។

២- ស្នើសុំអំណាចមេបាលើកូនប្រុសស្រី០២នាក់ ឈ្មោះ [redacted] ម៉ាណែត ភេទប្រុស កើតថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤ មានសំបុត្រកំណើតលេខ ០៧ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៤ របស់ចៅសង្កាត់កាចាញ និងឈ្មោះ [redacted] សុផារីន ភេទស្រី កើតថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩ មានសំបុត្រកំណើតលេខ ៣០ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣។

៣- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**២- ដំណើរការរឿងក្តី និងចំណុចវិវាទ**

**២.១. ការសង្ខេបអំពីរឿងក្តី**

នៅអំឡុងឆ្នាំ២០១៣ នាងខ្ញុំ និងឈ្មោះ [redacted] រ៉ានី បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ ០៩ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៣ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០១៣ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់កាចាយ ក្រុងបានលុង ខេត្តរតនៈគិរី។



Scanned with CamScanner

ក្រោយពីរៀបអាពាហ៍ពិពាហ៍នាងខ្ញុំ និងចុងចម្លើយ មានកូនចំនួន០២នាក់គឺ៖ ឈ្មោះ [redacted] រ៉ាម៉ាណែត ភេទប្រុស កើតថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤ មានសំបុត្រកំណើតលេខ ០៧ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៤ របស់ចៅសង្កាត់កាចាញ និងឈ្មោះ [redacted] សុផារីន ភេទស្រី កើតថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩ មានសំបុត្រកំណើតលេខ ៣០ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ របស់ចៅសង្កាត់កាចាញ។ ការរស់នៅជាមួយគ្នានាងខ្ញុំ និងចុងចម្លើយ មិនមានទ្រព្យសម្បត្តិរួម និងបំណុលរួមឡើយ។ នាងខ្ញុំសូមជម្រាបជូនបន្ថែមថា នៅក្នុងការរស់នៅជាប្តីប្រពន្ធតែងតែមានបញ្ហារកាំរកូស និងមិនមានភាពចុះសម្រុងនឹងគ្នារហូតមកដល់បច្ចុប្បន្ននេះ នាងខ្ញុំក៏អស់មនោសញ្ចេតនាមិនអាចរស់នៅជាប្តីប្រពន្ធតទៅទៀតដែរ។

## ២.២. ចំណុចដែលគ្មានវិវាទ

១- ដើមចោទទាមទារសិទ្ធិធ្វើជាអ្នកមានអំណាចមេបាលើកូនទាំង០២នាក់ កូនទី០១ ឈ្មោះ [redacted] រ៉ាម៉ាណែត និងកូនទី០២ ឈ្មោះ [redacted] សុផារីន **ចុងចម្លើយឯកភាព។**

២- ដើមចោទមិនទាមទារសោហ៊ុយចាំបាច់ក្នុងការគ្រប់គ្រងនិងថែរក្សាកូន **ចុងចម្លើយឯកភាព។**

៣- ដើមចោទ និងចុងចម្លើយ មិនមានទ្រព្យសម្បត្តិរួម និងទ្រព្យដោយឡែក។

## ២.៣. ចំណុចវិវាទ

១- ដើមចោទប្តឹងសុំលែងលះពីចុងចម្លើយ **ចុងចម្លើយមិនឯកភាព។** តើការសុំលែងលះរបស់ដើមចោទមានលក្ខណៈត្រឹមត្រូវតាមច្បាប់ដែរឬទេ?

២- ចុងចម្លើយទាមទារប្រាក់បណ្ណាការចំនួន ៣៦០០$ (បីពាន់ប្រាំមួយរយដុល្លាអាមេរិច) ដើមចោទមិនយល់ព្រម។ តើការសុំទាមទារប្រាក់បណ្ណាការចំនួន ៣៦០០$ (បីពាន់ប្រាំមួយរយដុល្លារអាមេរិច) របស់ចុងចម្លើយមានលក្ខណៈត្រឹមត្រូវតាមច្បាប់ដែរឬទេ?

## <u>សេចក្តីថ្លែងការណ៍របស់គូភាគី</u>

### ៣- ការអះអាងរបស់ដើមចោទ:

**-អ្នកតំណាងដោយអាណត្តិឱ្យដើមចោទបានថ្លែងការណ៍ថា៖** ខ្លួននៅតែប្តឹងទាមទារឱ្យតុលាការចេញសាលក្រមដូចមាននៅក្នុងពាក្យបណ្តឹងចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ និងដូចនៅក្នុងកំណត់ហេតុត្រៀមសម្រាប់ការទាញហេតុផលលើកទី០១ និងលើកទី០២ ទុកជាបានការដដែល ដែលមានខ្លឹមសារដូចខាងក្រោម៖

១- សុំសាលក្រមលែងលះប្តីឈ្មោះ [redacted] រ៉ានី។ **ដោយអះអាងថា:** ខ្លួន និងប្តីបានរៀបអាពាហ៍ពិពាហ៍តាមបែបលក្ខណៈប្រពៃណីខ្មែរនៅអំឡុងឆ្នាំ២០១៣ ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ០៩ សៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០១៣ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៣ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំកាចាញ។ មូលហេតុដែលខ្លួនប្តឹងសុំលែងលះ ដោយសារក្នុងការរស់នៅជាមួយគ្នាកន្លងមកខ្លួន និងចុងចម្លើយ មិនមានភាពចុះសម្រុងនឹងគ្នាដែលធ្វើឱ្យទំនាក់ទំនងក្នុងក្រុមគ្រួសារគ្មានសុភមង្គលឡើយ ហើយខ្លួននិង ប្តីបានរស់នៅបែកពីគ្នាអស់រយៈពេល០៣ឆ្នាំមកហើយ គឺចាប់តាំងពីឆ្នាំ២០២០ រហូតមកដល់ពេលបច្ចុប្បន្ន ធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាជាប្តីប្រពន្ធ តទៅទៀត។

២- ក្នុងការរួមរស់ជាមួយគ្នាបង្កើតបានកូនចំនួន០២នាក់ កូនទី០១ ឈ្មោះ [redacted] រ៉ាម៉ាណែត ភេទប្រុស កើតថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤ និងកូនទី០២ ឈ្មោះ [redacted] សុផារីន ភេទស្រី កើតថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩ ខ្លួនសុំសិទ្ធិជាអ្នកមានអំណាចមេបា។ **ដោយអះអាងថា:** សព្វថ្ងៃកូនទាំង០២នាក់រស់នៅជាមួយខ្លួនជាម្តាយ ហើយខ្លួនចង់ឱ្យកូនទាំង០២នាក់ រស់នៅជុំគ្នាដោយសារកូនៗនៅតូច ហើយខ្លួនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមពួកគាត់ដើម្បីផ្គត់ផ្គង់ឱ្យកូនរៀនសូត្រនិងមានពេលវេលាគ្រប់គ្រាន់ក្នុងការមើលថែកូនទាំង០២នាក់។



Scanned with CamScanner

៣- ខ្លួនមិនទាមទារសោហ៊ុយចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូនប្រុសស្រីទាំង០២នាក់ទេ ព្រោះខ្លួនមានលទ្ធភាពគ្រប់គ្រាន់អាចចិញ្ចឹមកូនទាំងពីរបាន។

៤- ចំពោះទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម គឺមិនមាននោះទេ។

**-ចុងចម្លើយឈ្មោះ [redacted] រ៉ានី បានធ្វើសេចក្តីថ្លែងការណ៍តបថា:** ខ្លួននៅតែរក្សាសេចក្តីថ្លែងការណ៍ដូចក្នុងកំណត់ហេតុត្រៀមសម្រាប់ការទាញហេតុផលលើកទី០១ និងលើកទី០២ ទុកជាបានការដដែល។

១- ការទាមទារលែងលះរបស់ដើមចោទ **ខ្លួនមិនឯកភាពទេ**។ ដោយសារដើមចោទចុះចោលខ្លួនមិនបានជូនដំណឹងមកខ្លួននោះទេ ហើយការរស់នៅជាមួយគ្នាកន្លងមកនៅមុនពេលដែលគាត់ចុះចេញ ខ្លួន និងចុងចម្លើយមានភាពចុះសម្រុងគ្នាជាធម្មតាទេ។ ខ្លួន និងដើមចោទ បានរស់នៅបែកលំនៅគ្នាអស់រយៈពេលជាង០៣ឆ្នាំមកហើយ រហូតមកដល់បច្ចុប្បន្ននេះ ដូចដើមចោទលើកឡើងពិតមែន។

២- ចំពោះអ្នកមានអំណាចមេបាលើកូនប្រុសស្រី០២នាក់ កូនទី០១ឈ្មោះ [redacted]ម៉ាណែត ភេទប្រុស កើតថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤ និងកូនទី០២ ឈ្មោះ [redacted]សុផារីន ភេទស្រី កើតថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩ ដែលដើមចោទសុំគ្រប់គ្រង **ខ្លួនមិនជំទាស់ទេ**។ ប្រសិនបើដើមចោទយល់ព្រមសងថ្លៃបណ្ណាការចំនួន ៣៦០០$ (បីពាន់ប្រាំមួយរយដុល្លារអាមេរិច) ឱ្យមកខ្លួនវិញ។

៣- ដើមចោទមិនទាមទារ សោហ៊ុយចាំបាច់ក្នុងការគ្រប់គ្រងនិងថែរក្សាកូន **ខ្លួនឯកភាព**។

៤- ចំពោះទ្រព្យដោយឡែក និងទ្រព្យរួម គឺមិនមានដូចដើមចោទលើកឡើងមែន។

**-ដើមចោទបានថ្លែងការណ៍តបថា៖** ខ្លួននៅតែសុំលែងលះពីចុងចម្លើយដដែល ហើយចំពោះប្រាក់បណ្ណាការដែលប្តីទាមទារចំនួន ៣៦០០$ (បីពាន់ប្រាំមួយរយដុល្លារអាមេរិច) នោះគឺ **ខ្លួនមិនយល់ព្រមទេ**។ ដោយពីមុនមកធ្លាប់បានធ្វើកិច្ចសន្យាព្រមព្រៀងលែងលះគ្នាដោយស្ម័គ្រចិត្ត ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២២ ដោយបានប្រគល់ប្រាក់ឱ្យចុងចម្លើយចំនួន ៥០០$ (ប្រាំរយដុល្លារអាមេរិច) និងបានសងអ៊ុំចុងចម្លើយឈ្មោះ [redacted]ហ៊ុច ចំនួន ១០០០$ (មួយពាន់ដុល្លារអាមេរិច) រួចហើយ។

**-ចុងចម្លើយថ្លែងការណ៍តប៖** ខ្លួនទទួលស្គាល់ថា បានធ្វើកិច្ចព្រមព្រៀងលែងលះដោយស្ម័គ្រចិត្ត ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២២ ប្រាកដមែន ប៉ុន្តែប្រាក់នោះខ្លួនបានទទួលចំនួន ៥០០$ (ប្រាំរយដុល្លារអាមេរិច) ហើយប្រាក់ចំនួន ១០០០$ (មួយពាន់ដុល្លារអាមេរិច) ទៀតនោះ ខ្លួនបានទទួលស្គាល់ថាបានសងទៅអ៊ុំប្រាកដមែន ប៉ុន្តែខ្លួននៅតែទាមទារប្រាក់ថ្លៃបណ្ណាការចំនួន ៣៦០០$ (បីពាន់ប្រាំមួយរយដុល្លារអាមេរិច) ដដែល។ ដែលប្រាក់នេះខ្លួនបានប្រគល់ឱ្យដើមចោទមុនពេលរៀបអាពាហ៍ពិពាហ៍។

## ការពិនិត្យភស្តុតាង

**ភស្តុតាងជាឯកសាររបស់ដើមចោទ៖**

១- សំបុត្រអាពាហ៍ពិពាហ៍លេខៈ ០៩ នៃសៀវភៅអាពាហ៍ពិពាហ៍លេខៈ ០១/២០១៣ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ ចេញមន្ត្រីអត្រានុកូលដ្ឋានឃុំកាចាញ។

២- សំបុត្រកំណើតកូនទី០១ ឈ្មោះ [redacted]ម៉ាណែត លេខៈ០៧ សៀវភៅកំណើតលេខ០១/២០១៤ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៤ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំកាចាញ។

៣- សំបុត្របញ្ជាក់កំណើតកូនទី០២ ឈ្មោះ [redacted]សុផារីន លេខៈ ៣០ សៀវភៅបញ្ជាក់កំណើតលេខៈ ០១/២៣ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំកាចាញ។

**ភស្តុតាងជាឯកសាររបស់ចុងចម្លើយ៖** (គ្មាន)។



Scanned with CamScanner

## សំអាងហេតុ

ឆ្លងតាមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាងនានា យល់ឃើញថា៖

១- តាមពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] ស្រីពៅ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់តុលាការអាចដោះស្រាយ និងវិនិច្ឆ័យបណ្តឹងនេះបានដោយផ្អែកតាមមាត្រា ៧ មាត្រា ១០ និងមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២- ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍នៅអំឡុងឆ្នាំ២០១៣ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ: ០៩ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ: ០១/២០១៣ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំកាចាញ។ ឃើញថាដើមចោទ និងចុងចម្លើយបានបំពេញលក្ខខណ្ឌស្របតាមមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី ដែលកំណត់ថាដើមចោទ និងចុងចម្លើយ គឺជាប្តីប្រពន្ធស្របច្បាប់។

៣- ដើមចោទបានទាមទារសុំលែងលះពីចុងចម្លើយ ដោយមូលហេតុក្នុងការរស់នៅជាប្តីប្រពន្ធតែងតែមានបញ្ហារកាំរកូស មិនមានភាពចុះសម្រុងនឹងគ្នារហូតមកដល់បច្ចុប្បន្ននេះ ធ្វើឱ្យអស់មនោសញ្ចេតនាមិនអាចរស់នៅជាប្តីប្រពន្ធតទៅទៀតដែរ ហើយខ្លួន និងចុងចម្លើយ រស់នៅបែកគ្នារយៈពេលជាង០៣ឆ្នាំមកហើយ។ ចុងចម្លើយមិនឯកភាពទេ ដោយសារដើមចោទចុះចោលខ្លួនមិនបានជូនដំណឹងមកខ្លួននោះទេ ហើយការរស់នៅជាមួយគ្នាកន្លងមកនៅមុនពេលដែលគាត់ចុះចេញ ខ្លួន និងចុងចម្លើយ មានភាពចុះសម្រុងគ្នាជាធម្មតាទេ។ ខ្លួនទទួលស្គាល់បានរស់នៅបែកគ្នាជាមួយដើមចោទរយៈពេលជាង០៣ឆ្នាំ ពិតមែន។ **តុលាការពិចារណាឃើញថា** ការប្តឹងទាមទាររបស់ដើមចោទមានមូលហេតុត្រឹមត្រូវតាមច្បាប់ ព្រោះថាដើមចោទបានរស់នៅបែកគ្នាជាមួយចុងចម្លើយរយៈពេលជាង០៣ឆ្នាំមកហើយ ចុងចម្លើយបានទទួលស្គាល់តាមការអះអាងរបស់ដើមចោទផងដែរ ដែលមូលហេតុនេះមានចែងក្នុងមាត្រា **៩៧៨ កថាខណ្ឌទី១** ចំណុច (ឃ) នៃក្រមរដ្ឋប្បវេណី ចែងថា ***"បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់រយៈពេលជាង០១ឆ្នាំ ផ្ទុយនឹងគោលបំណងអាពាហ៍ពិពាហ៍ គឺជាមូលហេតុនៃការលែងលះ"***។ ដូច្នេះគប្បីតុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទ។

៤- ក្នុងការរួមរស់ជាប្តីប្រពន្ធ ដើមចោទ និងចុងចម្លើយបង្កើតបានកូនចំនួន០២ (ពីរ)នាក់៖

៤.១- កូនទី០១ ឈ្មោះ [redacted] ម៉ាណែត ភេទប្រុស កើតថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤។

៤.២- កូនទី០២ ឈ្មោះ [redacted] សុផារីន ភេទស្រី កើតថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩។

ដើមចោទបានទាមទារអំណាចមេបាលើកូនទាំង០២ (ពីរ)នាក់ ហើយចុងចម្លើយក៏យល់ព្រមផងដែរ។ ដូច្នេះគប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី ស្របតាមមាត្រា ១០៣៧ **កថាខណ្ឌទី១** នៃក្រមរដ្ឋប្បវេណី។

៥- ចុងចម្លើយ ទាមទារប្រាក់ថ្លៃបណ្ណាការ (ជំនូន) ចំនួន៣៦០០$ (បីពាន់ប្រាំមួយរយដុល្លារអាមេរិច) ពីដើមចោទ **ដោយអះអាងថា:** ប្រាក់នេះគឺខ្លួនបានប្រគល់ឱ្យដើមចោទមុនពេលរៀបអាពាហ៍ពិពាហ៍ **ដើមចោទមិនយល់ព្រមទេ។** ចំណុចនេះតុលាការពិចារណាឃើញថា ការទាមទារនេះពុំមានលក្ខណៈត្រឹមត្រូវតាមច្បាប់នោះទេ ព្រោះការទាមទារនេះផ្ទុយទៅនឹងមាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណី ដែលបានចែងថា: ***"ក្នុងករណីដែលកំជាប់ពាក្យបានរលាយ ភាគីដែលលើកជំនូននៅពេលកំជាប់ពាក្យ ដោយសង្ឃឹមថានឹងបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារឱ្យភាគីម្ខាងទៀត សងជំនូននោះមកវិញបាន"***។ ប៉ុន្តែភាគីដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ០៩ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៣ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០១៣ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់កាចាយ រួចហើយ។ ដូច្នេះគប្បីតុលាការច្រានចោលការទាមទាររបស់ចុងចម្លើយ។

៦- ដើមចោទលះបង់ការទាមទារសោហ៊ុយចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូនពីចុងចម្លើយ។ ដូច្នេះគប្បីតុលាការមិនពិចារណាដល់បញ្ហានេះឡើយ។ Ꮙ



Scanned with CamScanner

៧- ដើមចោទដែលមានអំណាចមេបា និងគ្រប់គ្រងថែរក្សាកូន ត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីចុងចម្លើយក្នុងការផ្តត់ផ្គង់ សួរសុខទុក្ខ និងការប្រាស្រ័យទាក់ទងចំពោះកូនតាមផ្លូវច្បាប់ ស្របតាមមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី។

៨- ដើមចោទ និងចុងចម្លើយ ពុំមានទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម នោះទេ។ ដូច្នេះគប្បីតុលាការមិនពិចារណាដល់បញ្ហានេះឡើយ។

៩- ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយ ស្របតាមមាត្រា ៦៤ **កថាខណ្ឌទី១** នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**<u>សេចក្តីសម្រេចបញ្ចប់</u>**

១- លែងលះដើមចោទឈ្មោះ [redacted] **ស្រីពៅ** និងចុងចម្លើយឈ្មោះ [redacted] **រ៉ានី**។

២- ដើមចោទឈ្មោះ [redacted] **ស្រីពៅ** ជាអ្នកមានអំណាចមេបាលើកូនចំនួន០២នាក់ កូនទី០១ឈ្មោះ **ហមរ៉ា ម៉ាណែត** ភេទប្រុស កើតនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤ និងកូនទី០២ឈ្មោះ [redacted] **សុផារីន** ភេទស្រី កើតនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩។

៣- ដើមចោទមានអំណាចមេបាលើកូនត្រូវបង្កលក្ខណៈងាយស្រួលដល់ចុងចម្លើយក្នុងការផ្តត់ផ្គង់ សួរសុខទុក្ខ និងការប្រាស្រ័យទាក់ទងចំពោះកូនតាមផ្លូវច្បាប់។

៤- ច្រានចោលការទាមទារប្រាក់ថ្លៃបណ្តាការ(ជំនួន) ចំនួន ៣៦០០$ **(បីពាន់ប្រាំមួយរយដុល្លារអាមេរិច)** របស់ចុងចម្លើយ។

៥- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

-សាលក្រមនេះបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៅ**ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣** ចំពោះមុខដើមចោទ និងចុងចម្លើយ និងប្រកាសជាសាធារណៈនៅ**ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣**។ រក្សាសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា:** [redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃអង្គារ ១២រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្តាល, ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

កណ្តាល, ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner